**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលសន្និបាតបូកសរុបការងារឆ្នាំ២០១៥ និងទិសដៅឆ្នាំ២០១៦ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨

កាលពីថ្ងៃទី១៧ និង១៨ ខែកុម្ភៈ ឆ្នាំ២០១៦ នេះ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំសន្និបាតបូកសរុបការងារឆ្នាំ២០១៥ ទិសដៅឆ្នាំ២០១៦ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ២០១៤-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ និងមានការអញ្ជើញចូលរួមពីថ្នាក់ដឹកនាំរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សាក្រសួង តំណាងក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍជាតិ និងអន្តរជាតិ និងមន្ត្រីរាជការថ្នាក់ជាតិ និងក្រោមជាតិរបស់ក្រសួងចំនួន ៥០០នាក់។ ក្នុងរយៈពេល២ថ្ងៃនេះ សន្និបាតបានសម្រេចបាននូវលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**ក-លទ្ធផលការងារឆ្នាំ២០១៥**

**១-ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ**

- សហគ្រាស គ្រឹះស្ថាន ស្របតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ សរុបមានចំនួន ៨.១៩៧ គ្រឹះស្ថាន ដែលមានកម្មករនិយោជិតចំនួន ១.០៧៧.០៧៩នាក់
- បានចុះធ្វើអធិការកិច្ចការងារដោយក្រុមអធិការកិច្ចការងារតែមួយចំនួន ៩.១២២លើក (កើនឡើង ២៦,៩%) ដោយបាន៖
  - ដាក់កំហិតចំនួន ៦៤៨សហគ្រាស និងបានផាកពិន័យចំនួន ៣០សហគ្រាស ដែលមិនទាន់បានអនុវត្តពេញលេញនូវលក្ខខណ្ឌការងារ
  - ដកហូតនិងទប់ស្កាត់ពលកម្មកុមារចំនួន ២.៧០៨នាក់
  - រកឃើញរោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមានគិលានដ្ឋាន បន្ទប់រំលែក និងប្រអប់សង្គ្រោះបឋមត្រឹមត្រូវតាមច្បាប់កើនឡើងចំនួន ៣,៣%
- បានផ្សះផ្សានិងដោះស្រាយវិវាទការងារនៅតាមសហគ្រាសនានាចំនួន ៥២៩សហគ្រាស (កើនឡើង ៩,៥%) ដែលមានកម្មករនិយោជិតចំនួន ១៣១.៧២៨នាក់ (ថយចុះ ៦៣,៥%) ក្នុងនោះបានសះជាចំនួន៥២៧ករណី (កើនឡើង ៣១,៤%) មិនសះជាចំនួន ៦២៨ករណី (ថយចុះ ២,៨%) និងមោឃៈចំនួន ១១ករណី(ថយចុះ ៥២,២%)



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានបញ្ជូនករណីវិវាទទៅក្រុមប្រឹក្សាអាជ្ញាកណ្តាលចំនួន ៣៣៨ករណី (ថយចុះ ៦,៤%) ដោយបាន៖
    - សះជាដោយភាគីជម្លោះនិងដោយក្រុមប្រឹក្សាអាជ្ញាកណ្តាលចំនួន ៩៥ករណី(ថយចុះ ២៩,១%)
    - ចេញសេចក្តីបង្គាប់ចំនួន ២៣៦ករណី (កើនឡើង ៤,០%)
    - មិនទាន់ចេញសេចក្តីបង្គាប់ចំនួន ៧ករណី
- មានកូដកម្មកើតឡើងចំនួន ៣៣៦ករណី (ថយចុះ ១,៨%) ដែលមានកូដករសរុបចំនួន ៨២.៤៥៨នាក់ (ថយចុះ ៤០,១%) និងត្រូវបានដោះស្រាយសះជាចំនួន ៣២៦ករណី(ថយចុះ ១,៥%)
- បានពិនិត្យកាយសម្បទាកម្មករនិយោជិតចំនួន ២៤៣.០១១នាក់ (កើនឡើង ៣,៦%)
- បានសិក្សា សម្របសម្រួល និងសហការជាមួយអង្គការអន្តរជាតិខាងការងារ(ILO) ភាគីកម្មករនិយោជិត និងភាគីនិយោជក ពិភាក្សានិងកំណត់ប្រាក់ឈ្នួលអប្បបរមាផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៦ ពីចំនួន ១២៨ដុល្លារ ទៅ ១៤០ដុល្លារ (កើនឡើង ៩,៤%) ហើយបើគិតទាំងប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់អាចទទួលបានប្រាក់ចំណូលពី ១៥៧ដុល្លារ ទៅ ១៦៨ដុល្លារ ក្នុងមួយខែ
- បានចុះបញ្ជិកាអង្គការវិជ្ជាជីវៈចំនួន ២៣៧ (កើនឡើង ១១៣,៥%) ដែលជាសរុបមានសហជីពមូលដ្ឋានចំនួន ៣.៣៦៦ សហព័ន្ធសហជីពចំនួន ៩៧ សហភាពសហព័ន្ធសហជីពចំនួន ១៦ និងសមាគមនិយោជកចំនួន ៨
- បានទទួលស្គាល់ប្រតិភូបុគ្គលិកចំនួន ១.២០៣នាក់ (កើនឡើង ៥៣,១%)
- បានទទួលស្គាល់ភាពជាតំណាងបំផុតចំនួន ៤៣សហជីព (កើនឡើង ១៦,២%) និងបានចុះបញ្ជីអនុសញ្ញារួមចំនួន ៤៥ (កើនឡើង ២១.៦%)។

**២-ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ**

- បានចុះបញ្ជីគ្រឹះស្ថានក្រោមឱវាទក្រសួងសរុបចំនួន ១០៦(កើនឡើង ១៦,៥%) ក្នុងនោះគ្រឹះស្ថានសាធារណៈមានចំនួន ៣៩ (គ្រឹះស្ថានចំនួន១២ ទទួលបានវិញ្ញាបនបត្រ ISO ពីស្ថាប័នអន្តរជាតិលើការគ្រប់គ្រង)
- បានធ្វើការបណ្តុះបណ្តាលកម្រិតឧត្តម មធ្យម និងបឋម លើជំនាញឧស្សាហកម្ម បច្ចេកទេស សិប្បកម្ម សេវាកម្ម ទេសចរណ៍និងកសិកម្ម ដល់សិស្ស និស្សិតនិងសិក្ខាកាមសរុបចំនួន ៤៣.១៩៥នាក់ (កើនឡើង ៨៩%)
- បានរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ
- បានរៀបចំស្តង់ដាជាតិ និងកម្មវិធីសិក្សាផ្អែកលើសមត្ថភាពកម្រិត ២,៣,៤ សម្រាប់៦៣មុខរបរ ក្នុងវិស័យ Business ICT សំណង់ និងមេកានិច ព្រមទាំងបានបណ្តុះបណ្តាលគ្រូបច្ចេកទេសដើម្បីដំណើរការកម្មវិធីសិក្សាផ្អែកលើសមត្ថភាព (CBT) ចំនួន ២៣៧នាក់
- បានរៀបចំនិងចូលរួមការប្រកួតប្រជែងជំនាញថ្នាក់ជាតិដែលមានបេក្ខជនចំនួន ៨០នាក់ និងថ្នាក់អន្តរជាតិដោយមានបេក្ខជនចំនួន ២១នាក់
- បានធ្វើយុទ្ធនាការផ្សព្វផ្សាយបង្កើនការយល់ដឹងអំពី ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងការតម្រង់ទិសដល់អ្នកចូលរួមនិងសិស្សចំនួន ១.១០០នាក់
- បានធ្វើការហ្វឹកហ្វឺននិងធ្វើតេស្តកូនជាងចំនួន ១៣.៥៦០នាក់ (កើនឡើង ២១,៦%)។

**៣-ការអភិវឌ្ឍមុខរបរ និងការងារ**

- បានផ្តល់សេវាមុខរបរ និងរកការងារជូនប្រជាពលរដ្ឋចំនួន ៩៩.៧០៨នាក់ (ស្រី៦៦.៥០៨នាក់) ក្នុងនោះ៖
  - ការងារក្នុងប្រទេសបានចំនួន ៧៣.៤០៨នាក់(ស្រី៥៦.៥៣០នាក់)
  - ការងារក្រៅប្រទេសបានចំនួន ២៦.៣០០នាក់ (ស្រី៩.៩៧៨នាក់) ក្នុងនោះ៖
    - ប្រទេសថៃចំនួន ១៦.១៦៣នាក់ (ស្រី៦.៥៣៧នាក់)
    - កូរ៉េចំនួន ៧.៨៣២នាក់ (ស្រី១.៨៤២នាក់)
    - ជប៉ុនចំនួន ១.៣៩៩នាក់ (ស្រី៩១៥នាក់)
    - ម៉ាឡេស៊ីចំនួន ៨០៧នាក់ (ស្រី៥៨៥នាក់) និង
    - សឹង្ហបុរីចំនួន ៩៩នាក់ (ស្រី៩៩នាក់)

ស្ថានភាពពលករកម្ពុជា ដែលកំពុងធ្វើការនៅបរទេសបច្ចុប្បន្នមានចំនួន ៦១៩.៣៥៩នាក់ ក្នុងនោះប្រទេសថៃចំនួន ៥៣៣.៧០៧នាក់ ប្រទេសម៉ាឡេស៊ី ៣៨.៦៣៣នាក់ ប្រទេសកូរ៉េ ៤៤.៣៣០នាក់ ជប៉ុន ២.២៨៨នាក់ សឹង្ហបុរី ៤០១នាក់ ដែលក្នុងនោះចំណូលជាមធ្យមក្នុង១ឆ្នាំប្រមាណជាង ១.០០០ លានដុល្លារ។

- បានប្រមូលផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន ៤៩.៤៨៣នាក់ រៀបចំវេទិកា ពិព័រណ៍ និងសិក្ខាសាលាការងារថ្នាក់ជាតិនិងមូលដ្ឋានដោយមានអ្នកចូលរួមចំនួន ៤០.៣០៧នាក់ ព្រមទាំងផ្តល់សេវាណែនាំដល់អ្នកស្វែងរកការងារចំនួន ៣១.៧៣៣នាក់
- បានផ្តល់បណ្ណ និងសៀវភៅការងារដល់កម្មករនិយោជិតខ្មែរចំនួន ២០០.៩៧៤នាក់ (កើនឡើង ២១%) ផ្តល់បណ្ណ ផ្តល់សៀវភៅការងារ និងពន្យាសៀវភៅការងារដល់ជនបរទេសបានចំនួន ៣៥.៩១២នាក់ (កើនឡើង ១១២%) មកពី ១០៣ប្រទេស។

**៤-ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ**

- បានពង្រីកវិសាលភាពបេឡាជាតិរបបសន្តិសុខសង្គមនៅទូទាំង២៥ រាជធានី ខេត្ត ដោយមានសហគ្រាស គ្រឹះស្ថានចុះបញ្ជិកាចំនួន ៧.៧៩៦ (កើនឡើង ១១%) និងមានកម្មករនិយោជិតចំនួន ១.០៧៧.០៧៩នាក់ (កើនឡើង ៥%)
- បានធ្វើការអង្កេតរបាយការណ៍គ្រោះថ្នាក់ការងារចំនួន ៣០.៩១៩ (កើនឡើង ៥៩,២%) ក្នុងនោះមានកម្មករនិយោជិតរងគ្រោះចំនួន ៣០.២៨១នាក់ ព្រមទាំងបានផ្តល់តាវកាលិកហានិភ័យការងារចំនួន ២៨.៤៦២ឯកសារ ដល់ជនរងគ្រោះចំនួន ១៥.៣៣៨នាក់ (កើនឡើង ៤៤,២%)
- បានរៀបចំនីតិវិធីដាក់ឱ្យដំណើរការរបបថែទាំសុខភាពស្របតាមអនុក្រឹត្យលេខ០១អនក្រ.បក ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពសម្រាប់ជនទាំងឡាយណាដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ និងសិក្សាកសាងបទដ្ឋានគតិយុត្តសម្រាប់ដាក់អនុវត្តប្រព័ន្ធរបបសោធននៅឆ្នាំ២០១៧។

**៥-ការពង្រឹងអភិបាលកិច្ចល្អ**

- បានខិតខំបង្កើនប្រសិទ្ធភាពនិងគុណភាពសេវារដ្ឋបាលសាធារណៈ រួមមានការពង្រឹងយន្តការគ្រប់គ្រងការផ្តល់សេវា ការចរាចរលិខិតឯកសារ និងរៀបចំការិយាល័យច្រកចេញ-ចូលតែមួយ

- បានបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការទាន់ពេលវេលាតាមប្រព័ន្ធធនាគារ
- បានពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរដ្ឋ ដោយបានចូលរួមកៀរគរចំណូលសាធារណៈ បានចំនួន ១៦៥% និងបានអនុវត្តនីតិវិធីចំណាយបានចំនួន ៩៣% នៃច្បាប់ថវិកា
- បានអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ" ដោយរៀបចំថវិកាកម្មវិធីសម្រាប់អនុវត្តយុទ្ធសាស្ត្រអាទិភាព និងកំណែទម្រង់ទាំង៥ នៃការអភិវឌ្ឍវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨
- បានពង្រឹងនិងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ដោយបង្កើតឱ្យមានយន្តការសម្របសម្រួលការងារអន្តរជាតិពីគ្រប់នាយកដ្ឋាន
- បានរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំ រំកិល ផែនការយុទ្ធសាស្ត្រថវិកា ផែនការសកម្មភាពគ្រប់អង្គភាពក្រោមឱវាទ និងរាយការណ៍ទាន់ពេលវេលា
- បានបង្កើតបណ្ណាល័យក្រសួងសម្រាប់តម្កល់ឯកសារពាក់ព័ន្ធវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានពង្រឹងការងារសវនកម្មផ្ទៃក្នុងនិងអគ្គាធិការកិច្ច ដោយបង្កើតយន្តការសម្របសម្រួលផ្ទៃក្នុងចុះបេសកកម្មតែមួយ តែរបាយការណ៍ផ្សេងគ្នា
- បានខិតខំលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របតាមផែនការយុទ្ធសាស្ត្រស្តីពីនារីរតនៈទី៣។

## ខ. ទិសដៅអនុវត្តក្នុងឆ្នាំ២០១៦

បន្តជំរុញកំណែទម្រង់អាទិភាពទាំង៥ នៃការអភិវឌ្ឍវិស័យការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយប្រមូលផ្តុំលើសកម្មភាពសំខាន់ៗមួយចំនួន ៖

១-បន្តពង្រឹងនិងជំរុញការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងអនុសញ្ញាអន្តរជាតិពាក់ព័ន្ធ ធ្វើវិសោធនកម្មច្បាប់ស្តីពីការងារ ព្រមទាំងរៀបចំតាក់តែងបទប្បញ្ញត្តិ សំដៅធានានិងលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែល្អប្រសើរ សុខភាពនិងសុវត្ថិភាពការងារ និងសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ។

២-បង្កើនការចុះធ្វើអធិការកិច្ចការងារឱ្យបានចំនួនយ៉ាងតិច ១០.០០០លើក សំដៅបន្តលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិត និងនិយោជក និងកែប្រែឥរិយាបថនៃមន្ត្រីអធិការកិច្ចការងារឱ្យជិតស្និទ្ធជាមួយនឹងសហគ្រាស គ្រឹះស្ថាន និងកម្មករនិយោជិត។ សហការជាមួយកម្មវិធីរោងចក្រកាន់តែប្រសើររបស់អង្គការ ILO ដើម្បីសមាហរណកម្ម ប្រព័ន្ធអធិការកិច្ចទាំង២ ឱ្យស្របតាមច្បាប់ជាតិ និងអនុសញ្ញាអន្តរជាតិ។

៣-បន្តខិតខំដកហូត និងទប់ស្កាត់ពលកម្មកុមារដែលធ្វើការងារក្នុងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារជាពិសេស នៅតាមរោងចក្រកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង និងតំបន់កសិឧស្សាហកម្ម។

៤-បន្តខិតខំដោះស្រាយវិវាទការងារ ដោយធានានូវយុត្តិធម៌ជូនដល់គ្រប់ភាគីពាក់ព័ន្ធឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ព្រមទាំងខិតខំទប់ស្កាត់ការធ្វើកូដកម្ម បាតុកម្មខុសច្បាប់ដោយត្រូវអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់ ដើម្បីលុបបំបាត់និទណ្ឌភាពនិងធានាសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ។

៥-បញ្ចប់ការរៀបចំសេចក្តីព្រាងបទដ្ឋានគតិយុត្ត សម្រាប់ដាក់ឱ្យដំណើរការតុលាការការងារនៅឆ្នាំ ២០១៧។

៦-ជំរុញការអនុម័ត និងដាក់ឱ្យអនុវត្តច្បាប់ស្តីពីសហជីព។

៧-ជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥។

៨-បន្តជំរុញកិច្ចសហប្រតិបត្តិការលើការប្រើប្រាស់កម្លាំងពលកម្ម ជាមួយបណ្តាប្រទេសដៃគូ ដើម្បីបង្កើតឱកាសការងារបន្ថែម ធានានូវលក្ខខណ្ឌការងារ ការការពារសិទ្ធិ និងភាពស្របច្បាប់ របស់ពលករកម្ពុជានៅក្រៅប្រទេស។ ពង្រឹងការផ្តល់បណ្ណការងារពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេស និងរៀបចំគ្រប់គ្រងពលករទេសន្តប្រវេសន៍តាមប្រព័ន្ធអេឡិចត្រូនិច ដោយសហការជាមួយប្រទេសទទួល។

៩-អនុវត្តកម្មវិធីសិក្សា និងពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៧ សម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង តាមលក្ខណវិនិច្ឆ័យ យន្តការ និងកាលវិភាគដែលបានកំណត់។ សិក្សារៀបចំច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា។

១០-បន្តពង្រឹង និងពង្រីកគុណភាព កម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ទាំងរយៈពេលខ្លី និងរយៈពេលវែងឱ្យស្របទៅតាមតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគតឱ្យបានទូលំទូលាយរហូតដល់តំបន់ដាច់ស្រយាលទូទាំង២៥រាជធានី ខេត្ត។ បង្កើតមជ្ឈមណ្ឌលថ្នាក់ជាតិសម្រាប់ធ្វើតេស្តបញ្ជាក់សមត្ថភាព និងប្រកួតប្រជែងជំនាញថ្នាក់ជាតិឱ្យស្របទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិនិងស្តង់ដាជាតិសមត្ថភាព និងកម្មវិធីសិក្សាក្នុងតំបន់។

១១-បន្តលើកកម្ពស់ការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាព ដោយពង្រីកយន្តការ "វេទិកាការងារ" ឱ្យដល់មូលដ្ឋាន។ បង្កើតមជ្ឈមណ្ឌលការងារបន្ថែមចំនួន២ទៀត។

១២-រៀបចំដាក់ឱ្យអនុវត្តរបបធានារ៉ាប់រងសុខភាព និងសិក្សារៀបចំការដាក់ឱ្យដំណើរការរបបប្រាក់សោធន។

១៣-បង្កើនការផ្សព្វផ្សាយសុវត្ថិភាពចរាចរ និងការបង្ការទប់ស្កាត់គ្រោះថ្នាក់ការងារ ការដួលសន្លប់ឱ្យបាន២០០% នៃឆ្នាំ២០១៥។

១៤-ដាក់ឱ្យដំណើរការច្រកចេញចូលតែមួយ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការផ្តល់បណ្ណការងារ សៀវភៅការងារជនបរទេស តាមប្រព័ន្ធអេឡិចត្រូនិច។ រៀបចំឱ្យមានមជ្ឈមណ្ឌលទំនាក់ទំនងតាមបណ្តាញទូរស័ព្ទ និងបណ្តាញទំនាក់ទំនងសង្គមបែបទំនើប https://www.facebook.com/mlvt.gov.kh ជាមួយសាធារណជន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០១៦